CCC
គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

**ទស្សនវិស័យ:** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជា
**Vision:** Sustainable and democratic development in Cambodia

# របៀបវារៈ
# កិច្ចប្រជុំសម្រាប់អង្គការសមាជិក របស់ គ.ស.ក
## កាលបរិច្ឆេទ៖ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២
## ព្រឹកម៉ោង៖ ៨:០០ - ១២:០០

**សេចក្តីផ្តើម**

កិច្ចប្រជុំសម្រាប់សមាជិកលើកទី២៧០ គ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលឌីខេ *(ផ្លូវលេខ ៣៣០ ជិតសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង)* ដោយផ្អែកលើលក្ខន្តិកៈសម្រាប់សមាជិកភាព នៃអង្គការ គ.ស.ក កិច្ចប្រជុំសមាជិកត្រូវបានរៀបចំឡើងសម្រាប់អ្នកចូលរួម ដែលជាអ្នកតំណាងប្រចាំប្រទេស នាយកប្រតិបត្តិ និងអ្នកដឹកនាំជាន់ខ្ពស់ ឬអ្នកគ្រប់គ្រងនៃសមាជិករបស់ គ.ស.ក ដើម្បីចូលរួម ចែករំលែកចំណេះដឹង បទពិសោធន៍ កង្វល់ទូទៅលើបញ្ហាប្រឈមនៃការអភិវឌ្ឍ និងបញ្ហាសំខាន់ៗផ្សេងៗ របស់សមាជិកអង្គការ គ.ស.ក ដើម្បីធ្វើការដោះស្រាយរួមគ្នាផងដែរ។

ប្រជុំសមាជិកភាពអង្គការ គ.ស.ក នេះគឺធ្វើឡើងក្នុងគោលបំណង ដើម្បីចែករំលែក និងពិភាក្សាក្នុងចំណោមសមាជិក គ.ស.ក និងបច្ចុប្បន្នភាពនៃវឌ្ឍនភាពពីអង្គការ គ.ស.ក និងផែនការសំខាន់ៗ ក៏ដូចជាការចែករំលែកការងារសមាជិក និងផលប៉ះពាល់នៃការអនុលោមតាមច្បាប់ផ្សេងទៀតលើការងារសង្គមស៊ីវិល និងធាតុចូលសម្រាប់វេទិកាថ្នាក់ជាតិស្តីពីភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាល។ ដូច្នេះ វាអាចធ្វើអោយមានការឆ្លើយតបកាន់តែប្រសើរឡើងចំពោះការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនាពេលបច្ចុប្បន្ន បរិយាកាសសង្គមស៊ីវិល និងនិន្នាការផ្សេងទៀត។ កិច្ចប្រជុំលើកទី២៧០ នេះត្រូវបានរៀបចំឡើង ដើម្បីសម្រេចបាននូវគោលបំណងជាក់លាក់ដូចខាងក្រោម៖

- ស្វាគមន៍សមាជិកថ្មី ចែករំលែកពីការងាររបស់សមាជិក និងការថ្លែងអំណរគុណចំពោះសមាជិក។
- ប្រមូលធាតុចូលលើលំហរបស់អង្គការសង្គមស៊ីវិលសម្រាប់វេទិកាថ្នាក់ជាតិស្តីពីការសន្ទនាភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាល ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២។
- ផ្សេងៗ

**របៀបវារៈ**

| ម៉ោង | ខ្លឹមសាររបៀបវារៈ | អ្នកសម្របសម្រួល |
|---|---|---|
| ៨:០០ -៨:៣០ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គ.ស.ក |
| ៨:៣០ | គោរពភ្លេងជាតិ | អ្នកចូលរួមទាំងអស់ |
| ៨:៣០ -៩:០០ | **មតិស្វាគមន៍ និងបើកកម្មវិធី**<br>▪ ធ្វើបច្ចុប្បន្នភាពពី គសក សមិទ្ធផលការងារ និងផែនការ<br>▪ ស្ថានភាពសមាជិក និងវិភាគទានសមាជិកភាព | **លោកស្រី ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិ អង្គការ គ.ស.ក |
| ៩:០០-៩:៥០ | **ការចែករំលែក និងធ្វើបច្ចុប្បន្នភាពពីសមាជិក**<br>▪ បទបង្ហាញរបស់អង្គការ CUFA<br>▪ បទបង្ហាញរបស់អង្គការ SPOONS<br>*សំនួរ&ចំលើយ* | ▪ **លោក ម៉ៅ ឃី** នាយកប្រចាំប្រទេស អង្គការ CUFA<br>▪ **លោកស្រី ម៉ៅ សុផានី** នាយិកាប្រតិបត្តិអង្គការ SPOONS |
| ៩:៥០-១០:០៥ | រូបថតជុំគ្នា លិខិតថ្លែងអំណរគុណ និងការសម្រាកអាហារសម្រន់ | អ្នកចូលរួមទាំងអស់ |

| | | |
|---|---|---|
| ១០:០៥-១១:៣៥ | **ជាតុចូលរបស់អង្គការសង្គមស៊ីវិលសម្រាប់វេទិកាសន្ទនាភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២**<br>▪ ការណែនាំអំពីការសន្ទនាភាពជាដៃគូដោយ គ.ស.ក (**១០នាទី**)<br>▪ ការពិភាក្សាជាក្រុម៖ ក្តីកង្វល់ និងលំហរបស់អង្គការសង្គមស៊ីវិល នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (**៤០នាទី**)<br>▪ ចែករំលែកលទ្ធផលក្រុម និងការពិភាក្សាពេញអង្គ (**៤០នាទី**) | **លោកស្រី ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិ អង្គការ គ.ស.ក |
| ១១:៣៥-១២:០០ | **ផ្សេងៗ បូកសរុប និងមតិបិទកម្មវិធី**<br>▪ ការចាប់រង្វាន់សម្រាប់សមាជិក<br>▪ មតិបិទកម្មវិធី | **លោក Rune Kristian Dale-Andresen**<br>នាយកប្រចាំប្រទេសអង្គការ NPA និងជាគណៈកម្មាធិការប្រតិបត្តិ អង្គការ គ.ស.ក |
| | **ពិសារអាហារថ្ងៃត្រង់រួមគ្នា** | |

**សំគាល់៖**

- កិច្ចប្រជុំនេះបកប្រែជាភាសាខ្មែរ និងអង់គ្លេស
- អង្គការ គ.ស.ក សូមរក្សាសិទ្ធិក្នុងការកែសម្រួលរបៀបវារៈក្នុងករណីមានបញ្ហាប្រឈមលើពេលវេលា និងវាគ្មិន។
- ឯកសារផ្សេងៗរួមទាំងរូបភាព និងខ្លឹមសារសំខាន់ៗ នឹងត្រូវបានដាក់បញ្ចូលជាសាធារណៈក្នុងគេហទំព័រ និងប្រព័ន្ធទំនាក់ទំនងសង្គមរបស់អង្គការ គ.ស.ក សូមចូលតំណភ្ជាប់ផ្សេងៗ *http://www.ccc-cambodia.org/en/resources/event-archives* *www.facebook.com/CCCsince1990* *www.youtube.com/CCCambodia*
- សម្រាប់ការចូលរួមតាមអនឡាញ អាចចូលតាមតំណភ្ជាប់ **Join Zoom Meeting: https://us06web.zoom.us/j/88367239371**

**Meeting ID: 883 6723 9371**